សួស្តីអ្នកទាំងអស់គ្នា បាទ ថ្ងៃនេះយើងនឹងមានប្រធានបទមួយ ដើម្បីលើកយកមកនិយាយ
ដែលប្រធានបទរបស់យើងនៅក្នុងថ្ងៃនេះ គឺយើងនឹងនិយាយអំពីចោរឆក់ ចោរលួចកាបូប បាទ
អញ្ចឹងយើងនឹងនិយាយអំពីចោរលួចកាបូប អញ្ចឹងយើងមកមើលរូបភាពទាំងអស់គ្នាតែម្តង។

នៅក្នុងរូបភាពទី ១ យើងឃើញថាមានបុរសម្នាក់ គាត់កំពុងតែឈរនៅក្នុងស្ថានីយរថភ្លើង បាទ
បុរសនោះមានអាយុប្រហែលជា ២៥ ឆ្នាំ គាត់ពាក់អាវពណ៌ផ្កាឈូក ដៃខ្លី
ហើយគាត់ស្លៀកខោជើងវែងពណ៌ខ្មៅ បុរសនោះពាក់ស្បែកជើងប៉ាតាពណ៌ស
ហើយដៃម្ខាងរបស់គាត់កំពុងតែច្រត់ទៅក្នុងហោប៉ៅ បាទ ដៃម្ខាងរបស់គាត់ច្រត់ទៅក្នុងហោប៉ៅ
ឬក៏យើងអាចហៅម្យ៉ាងទៀតថា លូកទៅក្នុងហោប៉ៅ អញ្ចឹងដៃម្ខាងទៀតរបស់គាត់
កំពុងតែឈរចុចទូរស័ព្ទ បាទ គាត់កំពុងតែលេងទូរស័ព្ទជាមួយមិត្តភក្តិរបស់គាត់
ដូចជាគាត់កំពុងតែលេងសារ ឬក៏គាត់លេងឆាតទៅកាន់មិត្តភក្តិរបស់គាត់នៅក្នុងហ្វេសប៊ុក
ឬក៏ប្រព័ន្ធបណ្តាញសង្គមផ្សេងៗ ព្រោះថាបច្ចុប្បន្ននេះ មនុស្សយើងភាគច្រើន ជាពិសេសយុវវ័យ
គាត់ចូលចិត្តលេងឆាតនិងលេងបណ្តាញសង្គមជាមួយមិត្តភក្តិរបស់គាត់ខ្លាំងណាស់ ដូច្នេះហើយ
នៅពេលដែលគាត់កំពុងតែឈរ ឬក៏មានពេលទំនេរបន្តិចបន្តួច គាត់នឹងយកទូរស័ព្ទរបស់គាត់
ដើម្បីទំនាក់ទំនងទៅមិត្តភក្តិរបស់គាត់ជាក់ជាពុំខាន អញ្ចឹងដូចយើងឃើញនៅក្នុងរូបភាពនេះ
បុរសម្នាក់នោះ គាត់កំពុងតែចុចទូរស័ព្ទរបស់គាត់ ដើម្បីលេងជាមួយនឹងមិត្តភក្តិរបស់គាត់
នៅក្បែរបុរសម្នាក់នោះ យើងឃើញមានមនុស្សពីរនាក់ផ្សេងទៀត ដែលមួយនោះគឺជាមនុស្សស្រី
ដែលយើងឃើញគាត់ពាក់អាវដៃខ្លីនិងស្លៀកសំពត់ ហើយមានសក់វែង មនុស្សស្រីម្នាក់នោះ
គាត់កំពុងតែឈរកាន់កាបូបមួយ បាទ គាត់ឈរនៅក្បែរបុរសនោះ ដើម្បីរង់ចាំរថភ្លើងដូចគ្នា
ហើយនៅចំហៀងបុរសនោះមួយទៀត គឺមានបុរសម្នាក់ផ្សេងទៀត ដែលពាក់អាវពណ៌លឿងដៃខ្លី
បាទ ពួកគេកំពុងតែឈរចាំរថភ្លើងនៅក្នុងស្ថានីយរថភ្លើងមួយ
អញ្ចឹងជាទូទៅនៅក្នុងប្រទេសនីមួយៗតែងតែមានស្ថានីយរថភ្លើង ក៏ប៉ុន្តែនៅក្នុងប្រទេសកម្ពុជា
ស្ថានីយរថភ្លើងរបស់ប្រទេសកម្ពុជា គឺពុំទាន់ដំណើរការស្រួលបួលនៅឡើយទេ
ដូច្នេះនៅប្រទេសកម្ពុជា ឬក៏ប្រទេសខ្មែរ ពុំទាន់មានស្ថានីយរថភ្លើងដែលជាទីពេញនិយមនោះទេ
អញ្ចឹងប្រជាជនគាត់អត់ចូលចិត្តធ្វើដំណើរតាមរថភ្លើងនោះទេ ដោយសារតែវាពិបាក
យើងពុំទាន់មានផ្លូវរថភ្លើងគ្រប់ទីកន្លែង អញ្ចឹងហើយប្រជាជនចូលចិត្តធ្វើដំណើរតាមរថយន្ត
ឬក៏តាមឡាន តាមម៉ូតូជាដើម អញ្ចឹងមធ្យោបាយធ្វើដំណើរតាមរយៈរថភ្លើងនេះ
គឺយើងពុំសូវធ្វើដំណើរនោះទេ ប៉ុន្តែការធ្វើដំណើរតាមរថភ្លើងពេញនិយមនៅក្នុងប្រទេសផ្សេងទៀត
ដូចជាប្រទេសថៃ ប្រទេសវៀតណាម ប្រទេសម៉ាឡេស៊ីជាដើម អញ្ចឹងពួកគេមានស្ថានីយរថភ្លើង
ដើម្បីសម្រាប់ឲ្យប្រជាជនរបស់គេធ្វើដំណើរ។

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

នៅក្នុងរូបភាពទី ២ ចូលមកដល់រូបភាពទី ២ យើងឃើញថា បន្តិចក្រោយមក
រថភ្លើងមួយក៏បានមកដល់ អញ្ចឹងនៅពេលដែលរថភ្លើងមកដល់ គឺតែងតែមានសំឡេងខ្លាំងៗ បាទ
រថភ្លើងនៅប្រទេសកម្ពុជា គឺអត់លឿនទេ ល្បឿនវាគឺយឺត
ក៏ប៉ុន្តែនៅពេលដែលរថភ្លើងមកដល់ស្ថានីយម្តងៗ គឺមានសំឡេងលាន់យ៉ាងខ្លាំង
ដែលធ្វើឲ្យអ្នកនៅទីនោះដឹងយ៉ាងច្បាស់ថា រថភ្លើងកំពុងតែមកដល់ហើយ
អញ្ចឹងអ្នកដំណើរទាំងអស់អាចត្រៀមខ្លួននិងយកសម្ភារៈឬក៏អីវ៉ាន់របស់គេឡើងរថភ្លើងបាន
ដូចនៅក្នុងរូបភាពនេះ នៅពេលដែលរថភ្លើងមកដល់ តែងតែមានឲ្យនូវសញ្ញាមួយ
ដើម្បីបញ្ជាក់ប្រាប់អ្នកដំណើរថា រថភ្លើងបានមកដល់ហើយ អញ្ចឹងអ្នកដំណើរទាំងអស់
ត្រូវតែត្រៀមខ្លួន ដើម្បីឡើងរថភ្លើងទាំងអស់គ្នា។ យើងឃើញរថភ្លើងបើកមក គឺទ្វាររបស់រថភ្លើង
គឺបិទទាំងអស់ ព្រោះថាគេមិនអាចបើកទ្វាររថភ្លើងបានទេ ប្រសិនបើកំពុងធ្វើដំណើរ
ព្រោះអាចមានគ្រោះថ្នាក់ដល់អ្នកដំណើរ អញ្ចឹងយើងឃើញអ្នកដំណើរ
ដែលនៅក្រៅរថភ្លើងទាំងអស់ កំពុងតែឈរចាំរថភ្លើង ដើម្បីឲ្យរថភ្លើងឈប់និងបើកទ្វារ
បុរសម្នាក់ដែលពាក់អាវពណ៌ផ្កាឈូកនោះ គាត់កំពុងតែឈរកាន់ទូរស័ព្ទចុចដដែល
អញ្ចឹងបានន័យថាគាត់ចូលចិត្តលេងទូរស័ព្ទរបស់គាត់នៅពេលទំនេរខ្លាំងណាស់
ព្រោះថាអំឡុងពេលដែលគាត់ឈរចាំរថភ្លើង គឺគាត់ចុចទូរស័ព្ទលេងរហូត។

នៅក្នុងរូបភាពទី ៣ ចូលដល់រូបភាពទី ៣ យើងឃើញថា បន្ទាប់ពីរថភ្លើងមកដល់ហើយ
រថភ្លើងក៏ចាប់ផ្តើមឈប់ រំពេចនោះ ទ្វាររថភ្លើងក៏ចាប់បើកឡើង ហើយនៅពេលដែលទ្វាររថភ្លើងបើក
គឺអ្នកដំណើរទាំងអស់ គឺចៀសចេញពីទ្វាររថភ្លើង អញ្ចឹងយើងឃើញនៅក្នុងរូបភាពនេះ គឺទ្វាររថភ្លើង
គឺបើកចេញជាចំហៀង បានន័យថាទ្វាររថភ្លើងគឺមានពីរ បាទ មានពីរ
ដែលយើងឃើញថាមានទ្វារពីរនៅក្នុងច្រកចេញមួយ អញ្ចឹងទ្វារទាំងពីរនោះ គឺមិនបើកចូលក្នុង
ឬក៏ចេញក្រៅទេ ក៏ប៉ុន្តែទ្វារទាំងពីរគឺបើករុញទៅឆ្វេងនិងរុញទៅស្តាំ
ព្រោះថាប្រសិនបើយើងបើកចូលក្នុងឬចេញក្រៅ អាចបណ្តាលឲ្យប៉ះពាល់ដល់អ្នកដំណើរ
អញ្ចឹងអាចធ្វើឲ្យគាត់មានគ្រោះថ្នាក់ឬមានរបួសបាន ដូច្នេះនៅពេលដែលយើងរុញចេញខាងដូច្នេះ
គឺមិនមានអីប៉ះពាល់ដល់អ្នកដំណើរនោះទេ អញ្ចឹងហើយទើបទ្វាររថភ្លើង
គេធ្វើឲ្យរុញចេញទៅខាងទាំងអស់តែម្តង។ យើងឃើញនៅក្នុងរូបភាពនេះ អ្នកដំណើរទាំងអស់
ដែលនៅខាងក្រៅរថភ្លើង ដែលរង់ចាំចូលទៅក្នុងរថភ្លើងនោះ គាត់បានចៀសចេញពីទ្វាររថភ្លើង
ឬក៏ចៀសចេញពីផ្លូវចេញនៃរថភ្លើង ព្រោះថានៅពេលដែលរថភ្លើងឈប់
និងមានអ្នកដំណើរខ្លះចេញពីទ្វាររថភ្លើង ដូច្នេះអ្នកដំណើរដែលនៅខាងក្រៅ
ត្រូវរង់ចាំឲ្យអ្នកដំណើរដែលចេញ ចេញពីរថភ្លើងឲ្យអស់ ទើបគេអាចចូលបាន អញ្ចឹងហើយ
ប្រសិនបើគេឈរនៅខាងមុខផ្លូវដើរ ធ្វើឲ្យបាំង ឬក៏ធ្វើឲ្យស្ទះផ្លូវគេចេញមិនរួច

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

អញ្ចឹងធ្វើឲ្យមានការយឺតយ៉ាវដល់ការធ្វើដំណើរ ដូច្នេះដើម្បីឲ្យមានសុជីវធម៌ផង
និងដើម្បីកុំឲ្យស្ទះផ្លូវដល់គេផង ពួកអ្នកដំណើរដែលនៅខាងក្រៅ
ត្រូវតែចៀសចេញពីផ្លូវដែលគេដើរ។

ចូលដល់រូបភាពទី ៤ នៅក្នុងរូបភាពទី ៤ បន្ទាប់ពីទ្វាររថភ្លើងបើកហើយ យើងឃើញ
មានអ្នកដំណើរជាច្រើន មាន[អ្នកដំណើរ]ប្រុសស្រីជាច្រើន គាត់បានដើរចេញពីរថភ្លើង
ដែលឈប់នោះ អញ្ចឹងយើងឃើញថា អ្នកដំណើរដែលនៅខាងក្រៅ
គាត់មិនបានឈរនៅខាងមុខទ្វារនៃរថភ្លើងនោះទេ គឺគាត់ឈរទៅខាងទាំងអស់
ដូច្នេះហើយទើបពុំមានឲ្យមានការស្ទះផ្លូវ ឬក៏បាំងផ្លូវដល់អ្នកដំណើរដែលនៅខាងក្នុងនោះទេ
អញ្ចឹងអ្នកដំណើរដែលនៅខាងក្នុង គាត់បានចេញពីរថភ្លើងតាមសម្រួលម្តងមួយៗ
ដូច្នេះហើយទើបធ្វើឲ្យចំណាញ់ពេលវេលាបានច្រើន យើងឃើញមានអ្នកដំណើរជាច្រើន
ដែលគាត់ធ្វើដំណើរដល់គោលដៅរបស់គាត់ហើយចេញពីរថភ្លើង
ក៏ប៉ុន្តែមានអ្នកដំណើរមួយចំនួនទៀត គាត់ពុំបានចេញពីរថភ្លើងនោះទេ
ដោយហេតុថាគាត់ពុំទាន់ដល់គោលដៅរបស់គាត់ អញ្ចឹងការចេញពីរថភ្លើងគឺ
សម្រាប់តែអ្នកដំណើរណា ដែលគាត់ដល់គោលដៅរបស់គាត់ ទើបគាត់ចុះ អ្នកដំណើរណា
ដែលមិនទាន់ដល់គោលដៅ គឺគាត់ត្រូវបន្តដំណើរទៀត ដោយមិនបាច់ចុះពីរថភ្លើងនោះទេ។

ចូលដល់រូបភាពទី ៥ រូបភាពទី ៥ បន្ទាប់ពីអ្នកដំណើរដែលនៅខាងក្នុង គាត់ចេញអស់ហើយ បាទ
អ្នកដំណើរដែលដល់គោលដៅ គាត់ចេញពីក្នុងរថភ្លើងអស់ហើយ អ្នកដំណើរខាងក្រៅ
ដែលមានស្ត្រីម្នាក់និងបុរសពីរនាក់ ដែលបុរសម្នាក់ពាក់អាវផ្កាឈូកនោះ
គាត់ក៏បានចូលទៅក្នុងរថភ្លើងនោះម្តង អញ្ចឹងគាត់ចូលតាមទ្វារដែលបានបើករួចនោះទៅក្នុងរថភ្លើង
ដោយគាត់ដើរបណ្តើរ យកដៃរបស់គាត់ច្រត់ទៅក្នុងហោប៉ៅដដែល បាទ
អញ្ចឹងគាត់ដើរចូលទៅក្នុងរថភ្លើងតាមសម្រួល ដោយពុំមានការប្រញាប់ប្រញាល់
ឬក៏ដណ្តើមគ្នាចូលនោះទេ ព្រោះទ្វាររថភ្លើងបើកហើយធំ អញ្ចឹងផ្លូវដើរទូលាយ
ដូច្នេះគាត់ពុំចាំបាច់បញ្ច្រៀតគ្នានោះទេ។

ចូលមកដល់រូបភាពទី ៦ នៅក្នុងរូបភាពទី ៦ យើងឃើញថានៅក្នុងរថភ្លើងគឺមានមនុស្សច្រើន
ដូច្នេះកៅអីរថភ្លើងត្រូវបានគេអង្គុយអស់ហើយ អញ្ចឹងអ្នកដំណើរដែលចូលក្រោយ
ដែលអត់មានកៅអីអង្គុយគឺត្រូវឈរ អញ្ចឹងយើងឃើញ រូបភាពនេះ គឺមានមនុស្សជាច្រើន
កំពុងតែឈរនៅក្នុងរថភ្លើង ដោយពួកគេឈរជាជួរៗ ហើយដៃរបស់គេតោងទៅនឹងរបារមួយ
អញ្ចឹងនៅក្នុងរថភ្លើងឬក៏នៅក្នុងឡានក្រុងតែងតែមានរបារដែកមួយសម្រាប់ឲ្យអ្នកដំណើរតោង

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

ព្រោះថានៅពេលដែលពុំមានកៅអីគ្រប់គ្រាន់សម្រាប់ឲ្យអ្នកដំណើរអង្គុយ
អ្នកដំណើរទាំងអស់ត្រូវឈរ អញ្ចឹងដើម្បីទប់លំនឹងអ្នកដំណើរឲ្យបាននឹង កុំឲ្យដួល
ឬកុំឲ្យមានគ្រោះថ្នាក់ប៉ះទង្គិចផ្សេងៗ នៅក្នុងរថភ្លើង គេតែងតែដាក់របារដែកមួយ
ដើម្បីឲ្យអ្នកដំណើរឈរតោងវា ព្រោះថានៅពេលដែលចេញដំណើរ អ្នកដំណើរនឹងអាចនឹងដួល
ប្រសិនបើគេមិនតោង ដោយឡែកយើងឃើញបុរសម្នាក់ដែលពាក់អាវពណ៌ផ្កាឈូកនោះ
គាត់កំពុងតែឈរតោងទៅនឹងសសរនៅក្នុងរថភ្លើងមួយ ដែលគេដាក់សម្រាប់ឲ្យអ្នកដំណើរឈរ
អញ្ចឹងគាត់ទោះបីជាចូលទៅដល់ក្នុងរថភ្លើងហើយក៏ដោយ យើងឃើញថា
ដៃរបស់គាត់នៅតែចុចទូរស័ព្ទដដែល
ព្រោះគាត់កំពុងតែជក់ចិត្តនឹងលេងជាមួយនឹងមិត្តភក្តិរបស់គាត់នៅក្នុងទូរស័ព្ទ
ដូច្នេះហើយគាត់ពុំបានទុកទូរស័ព្ទគាត់នៅក្នុងហោប៉ៅវិញនោះទេ គឺគាត់ឈរកាន់
ដើម្បីចុចទូរស័ព្ទដដែល។ នៅខោរបស់បុរសនោះ យើងឃើញមានកាបូបលុយមួយ
ដែលដាក់នៅហោប៉ៅក្រោយ ដែលកាបូបលុយនោះ គឺពុំបានដាក់ឲ្យស៊ប់
ឬក៏ដាក់ឲ្យចូលជ្រៅទៅក្នុងហោប៉ៅនោះទេ គឺគាត់ដាក់នៅលៀនចេញក្រៅ
អញ្ចឹងកាបូបលុយរបស់គាត់ គឺលៀនចេញមកខាងក្រៅ
ដែលយើងអាចមើលឃើញកាបូបលុយរបស់គាត់ច្បាស់បាន។

រូបភាពទី ៧ រូបភាពទី ៧ គឺយើងឃើញហោប៉ៅរបស់បុរសនោះ ហោប៉ៅក្រោយ បាទ
ហោប៉ៅក្រោយរបស់បុរសនោះ មានកាបូបលុយមួយ អញ្ចឹង រូបភាពនេះ
គឺគាត់ដាក់កាបូបលុយនៅក្នុងហោប៉ៅក្រោយរបស់គាត់ ប៉ុន្តែកាបូបលុយនោះ
ពុំបានចូលជ្រៅទៅក្នុងហោប៉ៅនោះទេ គឺកាបូបលុយរបស់គាត់ គឺលៀនចេញមកក្រៅ បាទ
លៀនចេញមកក្រៅបន្តិច ដែលធ្វើឲ្យយើងមើលឃើញកាបូបលុយរបស់គាត់ច្បាស់ណាស់
កាបូបលុយរបស់គាត់គឺមានពណ៌លឿង។

ចូលដល់រូបភាពទី ៨ នៅក្នុងរូបភាពទី ៨ យើងឃើញថា មានដៃមួយ បាទ [ដៃជាអ្នក]
ជាដៃរបស់អ្នកដទៃនោះទេ បានលូកយក[...]កាបូបចេញពីហោប៉ៅរបស់គាត់
ដោយបុរសម្នាក់នោះពុំបានដឹងនោះទេ អញ្ចឹងការលូកយកសម្ភារៈរបស់អ្នកដទៃ
ដោយមិនមានការអនុញ្ញាតពីអ្នកដទៃ គេហៅថាលួច អញ្ចឹងបានន័យថា មានមនុស្សម្នាក់ទៀត
កំពុងតែលួចកាបូបរបស់បុរសម្នាក់នោះ ដោយបុរសម្នាក់នោះពុំបានដឹងខ្លួនថា
មានគេយកកាបូបលុយរបស់គាត់នោះទេ អញ្ចឹងអ្នកដែលលួចយើងហៅថាចោរ ដូច្នេះហើយ
ប្រសិនបើយើងទៅយករបស់គេ ឬក៏សម្ភារៈអ្នកដទៃ ឬក៏ទ្រព្យសម្បត្តិអ្នកដទៃ ដោយម្ចាស់របស់នោះ
មិនបានអនុញ្ញាតទេ គឺយើងហៅអ្នកដែលយកនោះហៅថាចោរ ដែលចោរគឺលួចរបស់អ្នកដទៃ

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

អញ្ចឹងមានមនុស្សម្នាក់កំពុងតែលួចកាបូបរបស់បុរសម្នាក់នោះ ពីក្នុងហោប៉ៅរបស់បុរសម្នាក់នោះ ដោយសារតែបុរសម្នាក់នោះ គាត់រវល់តែចុចទូរស័ព្ទលេងជាមួយមិត្តភក្តិ ដូច្នេះគាត់ពុំបានចាប់អារម្មណ៍ថា មាននរណាម្នាក់កំពុងតែយកកាបូបលុយរបស់គាត់នោះទេ។

នៅក្នុងរូបភាពទី ៩ នៅក្នុងរូបភាពទី ៩ យើងឃើញថា បន្តិចក្រោយមក រថភ្លើងក៏មកដល់គោលដៅទីពីរ អញ្ចឹងជាទូទៅផ្លូវរថភ្លើងនីមួយៗ គឺមានស្ថានីយរថភ្លើងជាច្រើន បាទ ស្ថានីយរថភ្លើងជាច្រើន ដូចថានៅពេលដែលទៅដល់គោលដៅមួយ គឺមានស្ថានីយរថភ្លើងមួយ ដូច្នេះគ្រប់ស្ថានីយទាំងអស់រថភ្លើងត្រូវតែឈប់ អញ្ចឹងពេលនៅដល់ស្ថានីយមួយៗ រថភ្លើងត្រូវតែឈប់ ដើម្បីដាក់អ្នកដំណើរចុះ និងឲ្យអ្នកដំណើរផ្សេងទៀតឡើង អញ្ចឹងហើយនៅក្នុងរូបភាពទី ៩ នេះ រថភ្លើងនោះបានមកដល់គោលដៅទីពីរ ដែលតម្រូវឲ្យរថភ្លើងនោះឈប់ ហើយបើកទ្វារឲ្យអ្នកដំណើរនៅខាងក្នុងចេញ និងអ្នកដំណើរនៅខាងក្រៅចូល។

ចូលមកដល់រូបភាពទី ១០ នៅក្នុងរូបភាពទី ១០ យើងឃើញថា បន្ទាប់ពីរថភ្លើងមកដល់គោលដៅទីពីរហើយ រថភ្លើងនោះក៏បានឈប់ ហើយរថភ្លើងបានបើកទ្វារ ដោយទ្វាររបស់រថភ្លើងនោះបើកចេញឆ្វេងស្តាំដូចមុនដែរ ហើយមានអ្នកដំណើរជាច្រើន មានប្រុស មានស្រី ដើរចេញពីក្នុងរថភ្លើងនោះ អញ្ចឹងយើងឃើញថា មានអ្នកដំណើរចេញពីទ្វារទាំងពីរនោះតែម្តង ដោយយើងឃើញមានបុរសពាក់អាវផ្កាឈូក ដែលមានវ័យ ២៥ ឆ្នាំនោះ ក៏បានចេញពីរថភ្លើងនោះផងដែរ ពេលនេះគាត់ដើរដោយយកដៃទាំងពីរជ្រែងហោប៉ៅ បានន័យថាយកដៃទាំងពីរ លូកទៅក្នុងហោប៉ៅសងខាងរបស់គាត់ ហើយគាត់បានដើរចេញមកក្រៅ ដោយពុំបានចាប់អារម្មណ៍អ្វីទាំងអស់ ដូច្នេះគាត់ពុំទាន់ដឹងថា មានមនុស្សលួចកាបូបរបស់គាត់នោះទេ។

ចូលមកដល់រូបភាពទី ១១ នៅក្នុងរូបភាពទី ១១ យើងឃើញថា បន្ទាប់ពីគាត់បានចេញពីក្នុងរថភ្លើងហើយ បុរសម្នាក់នោះ គាត់ក៏បានដើរមកកាន់ស្ថានីយរថភ្លើង អញ្ចឹងបន្ទាប់ពីចេញពីកន្លែងរថភ្លើង ឬក៏ចេញពីរថភ្លើង គឺយើងត្រូវដើរចូលទៅក្នុងស្ថានីយរថភ្លើង ព្រោះថា មុននឹងអាចជិះរថភ្លើងបាន យើងត្រូវតែទិញសំបុត្រនៅក្នុងស្ថានីយ ហើយមុននឹងអាច នៅពេលដែលយើងចុះពីលើរថភ្លើង យើងក៏ត្រូវដើរកាត់ស្ថានីយ ដើម្បីទៅខាងក្រៅផងដែរ អញ្ចឹងស្ថានីយរថភ្លើងនីមួយៗ តែងតែមាននូវជណ្តើរ ឬក៏ការចុះទៅខាងក្រោម ឬក៏ឡើងខាងលើ ទៅតាមផ្លូវរថភ្លើងរបស់គេថាតើគេនៅទាបឬនៅខ្ពស់ អញ្ចឹងរូបភាពនេះ

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

គឺផ្លូវរថភ្លើងរបស់គេគឺនៅខ្ពស់ ឬក៏អាចយើងហៅថា រថភ្លើងអាកាស អញ្ចឹងគឺរត់លើផ្លូវខ្ពស់ ដូច្នេះគឺត្រូវឡើងជណ្ដើរ ក៏ប៉ុន្តែដោយសារតែបុរសម្នាក់នោះចុះពីលើរថភ្លើង ដូច្នេះហើយគាត់ត្រូវចុះមកខាងក្រោមវិញ អញ្ចឹងបុរសម្នាក់នោះ គាត់ក៏បានជិះរថភ្លើង ជិះជណ្ដើរយន្ត ដើម្បីចុះមកខាងក្រោមចូលទៅក្នុងស្ថានីយ បាទ យើងឃើញថា ជណ្ដើរយន្តមួយនោះ គឺមានមនុស្សចំនួនប្រាំនាក់ ដែលកំពុងតែជិះជណ្ដើរយន្តនោះ ដោយនៅខាងមុខបុរសនោះ គឺមានមនុស្សពីរនាក់ ដែលខាង នៅ មនុស្សដែលនៅខាងមុខជាប់នឹងបុរសនោះ គាត់កំពុងតែឈរចុចទូរស័ព្ទ ហើយនារីដែលនៅខាងក្រោយបុរសនោះ គាត់កំពុងតែជិះជណ្ដើរយន្តដែរ ដោយដៃទាំងពីររបស់គាត់កំពុងតែកាន់កាបូបមួយ អញ្ចឹងបុរសម្នាក់នោះ គាត់កំពុងតែឈរនៅកណ្ដាល ដោយដៃរបស់គាត់កាន់នឹងបង្កាន់ដៃជណ្ដើរ បាទ ហើយដៃម្ខាងទៀតជ្រែងហោប៉ៅ ដោយគាត់ដាក់ដៃក្នុងហោប៉ៅ ហើយឈរបណ្ដើរសម្លឹងមើលទៅឆ្វេងស្ដាំបណ្ដើរនៅក្នុងស្ថានីយ ព្រោះថាពេលខ្លះយើងអាចចាប់អារម្មណ៍ទៅនឹងទិដ្ឋភាពនៅក្នុងស្ថានីយ ដែលមានរូបភាពប្លែកៗជាច្រើន។ ជណ្ដើរយន្ត យើងឃើញថា ជណ្ដើរយន្តគឺជាជណ្ដើរ ដែលយើងពុំចាំបាច់ឡើងជាន់កាំជណ្ដើរនោះទេ ដោយយើងគ្រាន់តែឈរមួយកន្លែង ពេលនោះជណ្ដើរយន្តនឹងនាំយើងឲ្យទៅខាងលើឬក៏ខាងក្រោមបាន ដោយយើងពុំចាំបាច់ចំណាយកម្លាំងនោះទេ ហើយជណ្ដើរយន្តគឺមានលក្ខណៈទំនើប ដូច្នេះហើយមានតែនៅក្នុងផ្សារទំនើប ឬក៏នៅក្នុងស្ថានីយរថភ្លើងទំនើបតែប៉ុណ្ណោះទើបមាន ដូច្នេះនៅក្នុងស្ថានីយរថភ្លើងរបស់ប្រទេសកម្ពុជាគឺពុំទាន់មានជណ្ដើរយន្តបែបនេះនោះទេ ក៏ប៉ុន្តែនៅក្នុងផ្សារទំនើប ឬក៏កន្លែងក្រុមហ៊ុនផ្សេងៗ គឺតែងតែមានជណ្ដើរយន្តជានិច្ច នៅក្នុងប្រទេសកម្ពុជាគឺមានជណ្ដើរយន្តជាច្រើនដាក់នៅក្នុងស្ថាប័ន ឬក៏ដាក់នៅក្នុងកន្លែងធ្វើការ ក៏ដូចជាផ្សារទំនើបផ្សេងៗផងដែរ។

ចូលដល់រូបភាពទី ១២ នៅក្នុងរូបភាពទី ១២ បន្ទាប់ពីបុរសម្នាក់នោះគាត់ជិះជណ្ដើរយន្តរួចហើយ គាត់ក៏បានដើរត្រូវតម្រូវដើរចូលស្ថានីយ ក៏ប៉ុន្តែមុននឹងគាត់អាចដើរចូលស្ថានីយរថភ្លើងបាន គឺគាត់ត្រូវតែមានសំបុត្រ អញ្ចឹងគាត់ដើរមកដល់កន្លែងមួយ គឺជាកន្លែងពិនិត្យសំបុត្រ បាទ កន្លែងត្រួតពិនិត្យសំបុត្រ ដូច្នេះគឺយើងឃើញមានថា មានផ្លូវដើរ[ចំនួន]ជាច្រើន ដែលមានរបង ឬក៏របាំងទ្វារ មិនអនុញ្ញាតឲ្យមនុស្សដើរឆ្លងកាត់បានដោយសេរីនោះទេ អញ្ចឹងរបាំងពណ៌ទឹកក្រូច គឺបាំងផ្លូវជិតតែម្ដង អញ្ចឹងបានន័យថា ទាល់តែយើងដាក់សំបុត្រចូល ឬក៏ដាក់កាតចូល ហើយម៉ាស៊ីនស្គាល់ទើបរបាំងនោះបើកទ្វារឲ្យមនុស្សដើរកាត់បាន អញ្ចឹងយើងឃើញថា បុរសម្នាក់នោះ បានមកដើរមកដល់ខាងមុខរបាំងនោះ ហើយរបាំងនោះ

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

ពុំទាន់បានបើកផ្លូវឲ្យបុរសនោះដើរនោះទេ អញ្ចឹងបុរសនោះចាំបាច់ត្រូវតែដាក់សំបុត្រ ឬក៏កាត ចូលទៅក្នុងម៉ាស៊ីន ដើម្បីឲ្យម៉ាស៊ីនបើកផ្លូវឲ្យ។

ចូលមកដល់រូបភាពទី ១៣ នៅក្នុងរូបភាពទី ១៣ បុរសម្នាក់នោះ គាត់ក៏បានងាកមកខាងក្រោយ ដើម្បីយកកាបូបរបស់គាត់ អញ្ចឹងបានន័យថាសំបុត្ររបស់គាត់ ឬក៏កាតរបស់គាត់ គឺទុកនៅក្នុងកាបូបលុយរបស់គាត់ ដូច្នេះហើយគាត់ក៏បានងាកមកខាងក្រោយ ហើយយកដៃមួយម្ខាងរបស់គាត់លូកមកហោប៉ៅខាងក្រោយ ដើម្បីដកយកកាបូបលុយ ព្រោះជាទូទៅមនុស្សប្រុសតែងតែទុកសម្ភារៈតូចៗផ្សេងៗ ដូចជាកាតបុគ្គលិក ដូចជាអត្តសញ្ញាណប័ណ្ណ ដូចជាលុយ ដូចជាសំបុត្រផ្សេងៗនៅក្នុងកាបូបលុយរបស់គាត់ ដើម្បីឲ្យមានសណ្ដាប់ធ្នាប់ ព្រោះថាប្រសិនបើយើងទុកនៅក្នុងហោប៉ៅ ឬក៏ទុកនៅកន្លែងផ្សេងទៀត វាអាចនឹងធ្វើឲ្យយើងវង្វេងបាត់ យើងមិនងាយស្រួលរកនោះទេ ក៏ប៉ុន្តែប្រសិនបើយើងទុកនៅក្នុងកាបូបលុយ គឺយើងនឹងងាយស្រួលយកមកវិញ ដូចបុរសនេះ គាត់បានទុកសំបុត្ររថភ្លើង ឬក៏កាតរបស់គាត់នៅក្នុងហោប៉ៅ ឬក៏នៅក្នុងកាបូបលុយ ដែលដាក់នៅក្នុងហោប៉ៅក្រោយ អញ្ចឹងនៅពេលដែលគាត់ត្រូវការ គាត់គ្រាន់តែងាកទៅខាងក្រោយ ហើយយកដៃលូកកាបូបលុយនោះជាការស្រេច។

ចូលដល់រូបភាពទី ១៤ នៅក្នុងរូបភាពទី ១៤ បុរសនោះបានភ្ញាក់ផ្អើលយ៉ាងខ្លាំង ព្រោះនៅពេលដែលគាត់លូកទៅក្នុងហោប៉ៅខាងក្រោយរបស់គាត់ គឺគាត់ពុំបានឃើញកាបូបលុយនោះទេ អញ្ចឹងនៅក្នុងរូបភាពនេះ យើងឃើញថា បុរសនោះ គាត់បានបើកភ្នែកធំៗ បាទ បើកភ្នែកធំៗ ភ្នែកទាំងពីររបស់គាត់ បើកយ៉ាងធំ ហើយគាត់បានហាមាត់ឡើង បាទ ជាទូទៅនៅពេលដែលមនុស្សយើងភ័យ ឬក៏មានការភ្ញាក់ផ្អើល យើងតែងតែបើកភ្នែកនិងហាមាត់ធំៗ ព្រោះថាយើងមានអារម្មណ៍ថាភ័យ អញ្ចឹងបុរសម្នាក់នោះ គាត់មានអារម្មណ៍ថាភ្ញាក់ផ្អើលនិងភ័យយ៉ាងខ្លាំង ព្រោះថាកាបូបលុយរបស់គាត់មិននៅក្នុងហោប៉ៅរបស់គាត់ទៀតទេ អញ្ចឹងហើយគាត់បានបើកភ្នែកធំៗ និងហាមាត់ធំៗផងដែរ។

ចូលដល់រូបភាពទី ១៥ នៅក្នុងរូបភាពទី ១៥ បន្ទាប់ពីបុរសនោះដឹងថា កាបូបលុយរបស់គាត់ត្រូវបានគេលួច ឬក៏កាបូបលុយរបស់គាត់ត្រូវបានបាត់ អញ្ចឹងហើយគាត់ក៏បានព្យាយាមងាកមើលជុំវិញខ្លួនគាត់ ដើម្បីរកមើលថាតើនរណាលួចកាបូបរបស់គាត់ ក៏ប៉ុន្តែយើងឃើញថានៅក្នុងរូបភាពនេះ គឺមានមនុស្សជាច្រើនកំពុងតែដើរទៅដើរមកនៅក្នុងស្ថានីយរថភ្លើង

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

ដោយគាត់ពុំអាចដឹងថានរណានោះទេ អញ្ចឹងហើយបុរសម្នាក់នោះ
គាត់ក៏មានអារម្មណ៍ថាសោកស្ដាយ និងមានអារម្មណ៍ថាភ័យយ៉ាងខ្លាំង
ព្រោះថាកាបូបលុយរបស់គាត់ត្រូវបានបាត់ គាត់បានព្យាយាមស្វែងរកមនុស្ស
ដែលលួចកាបូបលុយរបស់គាត់ ប៉ុន្តែគាត់ពុំដឹងថានរណានោះទេ ដោយរូបភាពនេះ គឺយើងឃើញថា
មានមនុស្សជាច្រើននៅក្នុងស្ថានីយរថភ្លើង ដោយមនុស្សនីមួយៗ គឺសុទ្ធតែគាត់មិនដែលស្គាល់
ហើយបានន័យថាចោរក៏បានរត់បាត់ទៅហើយ
ព្រោះថានៅពេលដែលគេលូកយកកាបូបលុយរបស់គាត់ហើយ ចោរតែងតែរត់ អញ្ចឹងដើម្បី ចោររត់
ព្រោះថាកុំឲ្យយើងចាប់បាន ជាទូទៅការលួចគេ គឺជាទង្វើខុសច្បាប់ ដូច្នេះប្រសិនបើគេចាប់បាន
គឺត្រូវមានទោសជាប់ពន្ធនាគារ អញ្ចឹងហើយ នៅពេលដែលលួចបាន ចោរក៏តែងតែរត់
ហើយប៉ូលិសក៏ត្រូវតែតាមចាប់ចោរមកវិញដែរ។ ប៉ុន្តែនៅក្នុងរូបភាពនេះ បុរសម្នាក់នោះ
គាត់បានព្យាយាមរកចោរដែលលួចកាបូប ប៉ុន្តែរកមិនឃើញនោះទេ
ដោយសារតែចោររត់បាត់ទៅហើយ ហើយនៅទីកន្លែងដែល នៅស្ថានីយរថភ្លើងនោះ
គឺមានមនុស្សជាច្រើន ដែលនៅក្នុងនោះ
ដូច្នេះគឺពិបាកនឹងរកឃើញថានរណាជាអ្នកលួចកាបូបលុយរបស់គាត់ណាស់។

ចូលមកដល់រូបភាពទី ១៦ នៅក្នុងរូបភាពទី ១៦ យើងឃើញថា បន្ទាប់ពីគាត់បាត់កាបូបលុយហើយ
គាត់មិនអាចដើរឆ្លងរបាំងដែលទៅម្ខាងទៀតនោះទេ ព្រោះថាម៉ាស៊ីនមិនបើកទ្វារឲ្យគាត់ដើរ
អញ្ចឹងហើយគាត់បានដើរត្រលប់ក្រោយមកវិញ បាទ អញ្ចឹងនៅពេលដែលគាត់ដឹងថា
គាត់បាត់កាបូបលុយ គាត់មិនបានធ្វើខុស ឬក៏គ្រលង ឬក៏កន្លងទ្វាររបាំងដែលនៅផ្លូវដើរនោះទេ
ព្រោះថាការធ្វើបែបនេះ គឺខុសទៅនឹងវិន័យរបស់ស្ថានីយរថភ្លើង អញ្ចឹងគេអាចនឹងចាប់គាត់បាន
ដូច្នេះគាត់បានដើរថយក្រោយ ព្រោះថាគាត់ ប្រសិនបើគាត់មិនត្រលប់ក្រោយទេ
អ្នកដំណើរផ្សេងទៀត គឺនឹងស្ទះ រាំងស្ទះ ដោយសារតែគាត់គេមិនអាចទៅមុខបាន
ព្រោះថាគាត់មិនអាចឆ្លងទៅបាន អញ្ចឹងបុរសម្នាក់នោះ ត្រូវតែដើរចេញពីកន្លែងច្រកចូលនោះ
ដើម្បីអ្នកដំណើរផ្សេងទៀត ដែលមានសំបុត្រ ឬក៏មានកាត គេដើរឆ្លងកាត់ផ្លូវនោះ។

ចូលដល់រូបភាពទី ១៧ នៅក្នុងរូបភាពទី ១៧ យើងឃើញថា បន្ទាប់ពីគាត់បាត់កាបូបហើយ
គាត់បានលូកក្នុងហោប៉ៅរបស់គាត់ ហោប៉ៅចំហៀង ដើម្បីយកទូរស័ព្ទ
អញ្ចឹងគាត់ទុកកាបូបលុយនៅក្នុងហោប៉ៅខាងក្រោយ បាទ ហើយទូរស័ព្ទនៅក្នុងហោប៉ៅចំហៀង
អញ្ចឹងជាទូទៅខោរបស់មនុស្សប្រុស គឺមានហោប៉ៅជាទូទៅចំនួនបី ដែលហោប៉ៅឆ្វេងមួយ
ហោប៉ៅស្ដាំមួយ និងហោប៉ៅក្រោយមួយ អញ្ចឹងហោប៉ៅឆ្វេងស្ដាំ គឺយើងទុកដាក់
ជាទូទៅយើងប្រើប្រាស់សម្រាប់ដាក់ទូរស័ព្ទនិងលុយបន្តិចបន្តួច ចំណែកហោប៉ៅក្រោយ

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

គឺយើងតែងតែដាក់នូវកាបូបលុយ ដូចបុរសម្នាក់នោះ
គាត់បានទុកទូរស័ព្ទគាត់នៅក្នុងហោប៉ៅចំហៀង ហើយកាបូបលុយនៅក្នុងហោប៉ៅក្រោយ
ដូច្នេះនៅពេលដែលគេលូកយក ឬក៏លួចយកកាបូបលុយរបស់គាត់ពីក្នុងហោប៉ៅក្រោយ
គាត់ពុំបានបាត់ទូរស័ព្ទនោះទេ ព្រោះទូរស័ព្ទរបស់គាត់ដាក់នៅក្នុងហោប៉ៅចំហៀង
អញ្ចឹងគាត់បានដកយកទូរស័ព្ទចេញពីហោប៉ៅចំហៀងមកចុច
យើងឃើញថាអាការៈរបស់គាត់ចុចទូរស័ព្ទគឺមានលក្ខណៈភ័យ
ព្រោះមានបែកញើសជាច្រើនចេញពីទឹកមុខរបស់គាត់ អញ្ចឹងមុខរបស់គាត់គឺបានបែកញើស
ដោយសារតែគាត់តក់ស្លុតនៅពេលដែលគាត់បាត់បង់កាបូបលុយរបស់គាត់
ព្រោះថាកាបូបលុយរបស់គាត់មានលុយ និងមានសម្ភារៈផ្សេងៗទៀត ដូចជាអត្តសញ្ញាណប័ណ្ណ
កាតបុគ្គលិក កាតក្រុមហ៊ុនជាដើម អញ្ចឹងហើយទើបធ្វើឲ្យគាត់មានអារម្មណ៍ថាស្ដាយនិងភ័យ
បែកញើសជាច្រើននៅលើមុខ។

បន្ទាប់មកទៀត នៅក្នុងរូបភាពទី ១៨ នៅក្នុងរូបភាពទី ១៨ បុរសម្នាក់នោះ
គាត់ក៏បានទូរស័ព្ទទៅរកមិត្តភក្តិរបស់គាត់ អញ្ចឹងគាត់បានទាញទូរស័ព្ទចេញពីហោប៉ៅ
ម្ដងនេះគាត់ពុំបានចុចទូរស័ព្ទលេងបណ្ដាញ[...]សង្គម ឬក៏ហ្វេសប៊ុក
ឬក៏ឆាតទៅមិត្តភក្តិរបស់គាត់ទៀតនោះទេ ប៉ុន្តែគាត់បានយកទូរស័ព្ទមក
ដើម្បីនិយាយទៅកាន់មិត្តភក្តិរបស់គាត់ គាត់បានទូរស័ព្ទទៅកាន់មិត្តភក្តិរបស់គាត់
ហើយរៀបរាប់អំពីរឿងរ៉ាវដែលចោរលួចកាបូបលុយរបស់គាត់ ដោយគាត់រៀបរាប់បណ្ដើរ
ធ្វើកាយវិការបណ្ដើរ អញ្ចឹងគាត់បានលើកដៃឡើង ហើយគាត់បាននិយាយ ហាមាត់និយាយ
ដោយពិពណ៌នាទៅលើអ្វីដែលបានកើតឡើងចំពោះគាត់ ដូចជាគាត់ឈរចុចទូរស័ព្ទនៅក្នុងរថភ្លើង
ពេលនោះមានចោរមួយ គាត់ក៏បានលូកចូលក្នុងហោប៉ៅក្រោយរបស់គាត់
ដើម្បីដកយកកាបូបរបស់គាត់ចេញពីហោប៉ៅ អញ្ចឹងនៅពេលដែលចោរដកចេញ
ដកកាបូបចេញពីហោប៉ៅគាត់ពុំបានដឹងខ្លួននោះទេ ដូច្នេះហើយទើបធ្វើឲ្យគាត់បាត់កាបូបលុយ
អញ្ចឹងគាត់បានខលទៅប្រាប់មិត្តភក្តិរបស់គាត់ថាគាត់បានបាត់កាបូបលុយ
ហើយដើម្បីឲ្យមិត្តភក្តិរបស់គាត់មកជួយគាត់ ដើម្បីទិញសំបុត្ររថភ្លើងថ្មី ដើម្បីអាច
ឲ្យគាត់បន្តដំណើរទៅខាងមុខទៀត អញ្ចឹងលុះត្រាតែគាត់មានសំបុត្ររថភ្លើងថ្មី
ទើបគាត់អាចដើរឆ្លងកាត់ផ្លូវដើរដែលមានរបាំងនោះបាន ដូច្នេះហើយគាត់ខលទៅមិត្តភក្តិរបស់គាត់
ដើម្បីស្វែងរកជំនួយ ឲ្យមិត្តភក្តិរបស់គាត់ទិញសំបុត្ររថភ្លើងមួយឲ្យគាត់
ដើម្បីឆ្លងកាត់របាំងម៉ាស៊ីនរបាំងផ្លូវនោះ ដើម្បីឲ្យគាត់ធ្វើដំណើរទៅមុខទៀតបាន។

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.